អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំកម្ពុជា – ភ្នំពេញ

# សេចក្តីថ្លែងការណ៍

## ដោយអ្នកជំនាញការចំនួន១៣ រូប របស់អង្គការសហប្រជាជាតិ

## " ស្តីពីគំនិតផ្តួចផ្តើមពាក់ព័ន្ធនឹងការឃុំឃាំងជាសកល "

ថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៨

*អ្នកជំនាញការឯករាជ្យចំនួន១៣ រូប របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានចេញសេចក្តីថ្លែងការណ៍ខាងក្រោម នៅពេលចាប់ផ្តើមសប្តាហ៍ស្តីពីសេចក្តីថ្លៃថ្នូរ និងយុត្តិធម៌ សំរាប់អ្នកជាប់ឃុំឃាំង - គំនិតផ្តួចផ្តើមជាសកលមួយដែលបានបើកយុទ្ធនាការដោយឧត្តមស្នងការសិទ្ធិមនុស្ស ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី៦-១២ ខែតុលា ឆ្នាំ២០០៨។*

**ទីក្រុងហ្សឺណែវ** - " យើងខ្ញុំសូមសំដែងការគាំទ្រយ៉ាងខ្លាំងក្លាចំពោះគំនិតផ្តួចផ្តើមរបស់ឧត្តមស្នងការស្តីពីការលើកកំពស់ការគោរពសិទ្ធិអ្នកជាប់ឃុំឃាំង។ ក្នុងនាមជាអ្នកប្រតិបត្តិអាណត្តិនៃនីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស យើងខ្ញុំធ្វើទស្សនកិច្ចទៅកាន់កន្លែងឃុំឃាំងនានានៅក្នុងប្រទេសជាច្រើននិងទទួលព័ត៌មាននៅជុំវិញពិភពលោក។ បញ្ហាធ្ងន់ធ្ងរមួយដែលយើងខ្ញុំតែងជួបប្រទះជារឿយៗនោះគឺការមិនមានកំណត់ហេតុត្រឹមត្រូវអំពីជនដែលត្រូវបានដកហូតសេរីភាព ឬធ្ងន់ធ្ងរជាងនេះទៀតនោះគឺជនទាំងនោះត្រូវបានគេដាក់នៅកន្លែងឃុំឃាំងដែលមិនមានការទទួលស្គាល់ជាផ្លូវការ។ នេះក៏ជាកង្វល់ខ្លាំងផងដែរថា មនុស្សជាច្រើន មិនគួរត្រូវបានដកហូតសេរីភាព ដោយសារតែការឃុំឃាំងតាមទំនើងចិត្ត ឬដោយបំពាននោះទេ។ មនុស្សខ្លះទៀតកំពុងជាប់ឃុំឃាំងដោយផ្អែកទាំងស្រុងលើបញ្ជារដ្ឋបាល ដែលមិនពាក់ព័ន្ធនឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឡើយ ឧទាហរណ៍ ជនអន្តោប្រវេសន៍ខុសច្បាប់។ ការដកហូតសេរីភាពដូចនេះ ទោះជាស្របច្បាប់ ឬមិនស្របច្បាប់ក្តី ធ្វើឱ្យមនុស្សទាំងឡាយងាយនឹងរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស។

កន្លែងឃុំឃាំងមួយចំនួនបានរិតត្បិតហួសហេតុលើសិទ្ធិអ្នកជាប់ឃុំឃាំង ដោយរួមទាំងសិទ្ធិទទួលបានកិច្ចគាំពារសុខភាព និងសិទ្ធិខាងម្ហូបអាហារ សិទ្ធិអប់រំ សិទ្ធិឯកជន ជីវិតរស់នៅរបស់គ្រួសារ និងសិទ្ធិចូលរួមក្នុងជីវភាពនយោបាយនៃប្រទេសខ្លួន។ ករណីធ្ងន់ធ្ងរជាងនេះនោះគឺ ការដាក់អ្នកទោសច្រើនហួសចំណុះ ការខ្វះខ្យល់អាកាស និងពន្លឺថ្ងៃ ហើយអនាម័យមិនស្របតាមកំរិតស្តង់ដាក្នុងកន្លែងឃុំឃាំង ជាហេតុធ្វើឱ្យអ្នកទោសមានជម្ងឺ ដែលស្ថានភាពបែបនេះនាំឱ្យមានការរាលដាលនៃជម្ងឺ។

ជនដែលត្រូវបានដកហូតសេរីភាព ប្រឈមមុខនឹងការកើនឡើងនៃហានិភ័យនៃការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញ និងករណីធ្ងន់ធ្ងរមួយចំនួន ដូចជាការបាត់ខ្លួនដោយបង្ខំ។ ទំហំរូបភាពនៃអំពើហិង្សាដែលយើងបានឃើញផ្ទាល់ភ្នែកនៅតាមអាគារឃុំឃាំងនានាមានលក្ខណៈធំធេញ ដោយមានទាំងការវាយដំ និងការឆក់ខ្សែភ្លើងលើរាងកាយ ការគំរាមកំហែង ការគាបសង្កត់ ការធ្វើឆេះរលាក ការយកម្ជុលចាក់ចូលក្នុងក្រចកដៃ ការបាញ់ប្រហារ ការដាក់ឱ្យដេកផ្ងាចងដៃជើងលើបន្ទះក្តាររួចចាក់ទឹកស្រោចលើមុខចូលតាមផ្លូវដង្ហើម និងអំពើហិង្សាផ្លូវភេទ។ ជាអកុសល មធ្យោបាយធ្វើទារុណកម្មមិនមែនមានតែត្រឹមប៉ុណ្ណឹងនោះទេ គឺគេបានបង្កើតវិធីច្រើនទៀតដើម្បីធ្វើទារុណកម្មមនុស្ស។

ជាញឹកញយបំផុត យើងបានឃើញថាការរើសអើងកើតមានក្នុងសង្គមទូទៅ ហើយការដែលអាក្រក់ជាងនេះនោះគឺការដកហូតសេរីភាពបុគ្គល។ សូម្បីតែមានគោលនយោបាយ និងការអនុវត្តន៍សំដៅឱ្យមនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាក្តី ក៏ជារឿយៗគេតែងមើលរំលងអំពីសេចក្តីត្រូវការរបស់ស្ត្រី អនីតិជន ជនមិនមែនជាពលរដ្ឋខ្លួន អ្នកជម្ងឺ និងជនពិការ។ អ្នកជាប់ឃុំឃាំងដែលក្រីក្រត្រូវបានគេដាក់ច្រើនហួសចំណុះ ហើយជារឿយៗសិទ្ធិរបស់ពួកគេក្នុងការទទួលបានកិច្ចគាំពារសុខភាព និងម្ហូបអាហារត្រូវបានកាត់បន្ថយជាអប្បបរមា។ អ្នកជាប់ឃុំឃាំងដែលមានផ្ទះសម្បែងនៅឆ្ងាយ មិនបានទទួលការជួយឧបត្ថម្ភពីក្រុមគ្រួសារ។ សមាជិកនៃក្រុមឬស្ត្រីងាយរងគ្រោះដោយអំពើហិង្សាផ្លូវភេទ និងការប្រព្រឹត្តដូចទាសករក្នុងកន្លែងឃុំឃាំង ហើយជារឿយៗករណីនេះមានការយល់ព្រមដោយស្ងៀមស្ងាត់ពីមន្ត្រីរដ្ឋាភិបាល ឬមន្ត្រីរដ្ឋាភិបាលជាអ្នកប្រព្រឹត្តដោយផ្ទាល់។ ជារឿយៗគេប្រើសេវាឃុំឃាំងធ្វើជាមធ្យោបាយមួយសំរាប់ដាក់ទណ្ឌកម្មមនុស្ស ដោយមិនផ្តល់ឱកាសអប់រំកែប្រែឡើយ ដូច្នេះវារិតតែធ្វើឱ្យអ្នកជាប់ឃុំឃាំងធ្លាក់ក្នុងសភាពអាក្រក់ថែមទៀត ច្រើនជាងការជួយឱ្យពួកគេរៀបចំខ្លួនសំរាប់ការដោះលែងឱ្យមានសេរីភាព។

ដោយហេតុថា ការរំលោភសិទ្ធិអ្នកជាប់ឃុំឃាំង តាមនិយមន័យមានភាពសំងាត់ ហើយនៅកន្លែងជាច្រើន មិនមានបណ្តាញណាដែលមានប្រសិទ្ធភាពក្នុងការលុបចោលនិយមន័យទាំងនោះ ទើបអំពើអយុត្តិធម៌ទៅលើអ្នកជាប់ឃុំឃាំង មិនមានអ្នកណាម្នាក់ទទួលខុសត្រូវឡើយ។

នៅក្នុងឱកាសនៃសប្តាហ៍ស្តីពី " សេចក្តីថ្លៃថ្នូរ និងយុត្តិធម៌សំរាប់អ្នកជាប់ឃុំឃាំង" យើងសូមអំពាវនាវដល់រដ្ឋទាំងអស់ឱ្យខិតខំប្រឹងប្រែងយកអស់ពីសមត្ថភាពដើម្បីធានាថាអ្នកជាប់ឃុំឃាំងទាំងឡាយ ដូចជាមនុស្សដទៃទៀតដែរ គប្បីត្រូវបានគេប្រព្រឹត្តដោយការគោរព និងសេចក្តីថ្លៃថ្នូរ។ យើងខ្ញុំក៏សូមអំពាវនាវផងដែរ ដល់រដ្ឋនានា ដើម្បីផ្តល់ឱ្យមានយន្តការធ្វើពាក្យបណ្តឹង និងយន្តការតាមឃ្លាំមើលប្រកបដោយប្រសិទ្ធភាពនៅកន្លែងឃុំឃាំងនានា ដោយរួមទាំងមធ្យោបាយតវ៉ាអំពីនីត្យានុកូលភាពនៃការឃុំឃាំង និងការទទួលបានសេវាប្រឹក្សាយោបល់ផ្នែកច្បាប់ ក្នុងគោលបំណងធ្វើឱ្យសិទ្ធិមនុស្សក្លាយជាការពិតសំរាប់អ្នកជាប់ឃុំឃាំង។

**<u>ហត្ថលេខីៈ</u>**

**លោក ហ្វីលីព អាលស្តុនៈ** អ្នករាយការណ៍ពិសេសស្តីពីការសំលាប់ក្រៅច្បាប់ឬការសំលាប់តាមទំនើងចិត្ត។

**លោក ហូច ប៊ូស្តេមិនត៍ :** អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមនុស្សរបស់ទេសន្តរប្រវេសន៍។

**លោកស្រី ម៉ានូអែលឡា ខាមិនណ ខាស្ត្រីលឡូ :** ប្រធាន - អ្នករាយការណ៍នៃក្រុមការងារស្តីពីការឃុំឃាំងតាមទំនើងចិត្តរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។

**លោក សាន់ត្យាហ្គោ គ័រគូរ៉ា ខាបេហ្សុត :** ប្រធាននៃក្រុមការងារស្តីពីការបាត់ខ្លួនដោយបង្ខំ ឬដោយមិនស្ម័គ្រចិត្ត។

**លោក អូលីវីយេ៉ ឌឺ សុតតេ :** អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិទទួលបានស្បៀងអាហារ។

**លោក លីនដ្រូ ដេសពួយ :** អ្នករាយការណ៍ពិសេសស្តីពីឯករាជ្យភាពនៃចៅក្រម និងមេធាវី។

**លោកស្រី យ៉ាគីន អេីរទៀក :** អ្នករាយការណ៍ពិសេសស្តីពីអំពើហឹង្សាប្រឆាំងនឹងស្ត្រី បុព្វហេតុ និងផលវិបាករបស់វា ។

**លោក អាណន់ ហ្គ្រូវើរ :** អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិពលរដ្ឋគ្រប់រូបចំពោះការទទួលបានបទដ្ឋានកំរិតខ្ពស់បំផុតខាងសុខភាពផ្លូវកាយ និងផ្លូវចិត្ត។

**លោក វើរន័រ មុនណូស :** អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិអប់រំ។

**លោក ម៉ែនហ្វ្រិត ណូវ៉ាក :** អ្នករាយការណ៍ពិសេសស្តីពីការប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។
**លោក ម៉ាទីន សៃនីន :** អ្នករាយការណ៍ពិសេសស្តីពីការលើកស្ទួយនិងការការពារសិទ្ធិមនុស្ស ខណៈពេលធ្វើការប្រឆាំងនឹងភេរវកម្ម ។
**លោកស្រី ម៉ាកដាលែនណា សេពុលវេដា :** អ្នកជំនាញការឯករាជ្យស្តីពីបញ្ហាសិទ្ធិមនុស្ស និងភាពក្រីក្របំផុត។
**លោកស្រី ហ្គុលណារ៉ា ហ្សាហ៊ីនៀន :** អ្នករាយការណ៍ពិសេសស្តីពីទម្រង់នៃទាសភាព ដែលកើតមានក្នុងសហសម័យ បុព្វហេតុ និងផលវិបាករបស់វា ។

*សំរាប់ព័ត៌មានបន្ថែមអំពីគំនិតផ្តួចផ្តើមសំរាប់ការឃុំឃាំង សូមបើកគេហទំព័រពិសេស : www.ohchr.org ដែលមានចំណងជើងថា " សេចក្តីថ្លៃថ្នូរ និងយុត្តិធម៌ សំរាប់សប្តាហ៍អ្នកជាប់ឃុំឃាំង " ។*

**ចប់**